# ប្រទេសកម្ពុជាៈ ការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិថ្កោលទោសចំពោះការប្រើកម្លាំងជ្រុលហួសហេតុទៅលើអ្នកតវ៉ា

ញូវយ៉ក ថ្ងៃទី ៧ ខែ មករា ឆ្នាំ ២០១៤ ម៉ោង ១១ ព្រឹក

តាមគេហទំព័រ<"http://www.ohchr.org/EN/NewsEvents/Pages/DisplayNews.aspx?NewsID=14152&LangID=E"> នៅថ្ងៃនេះ ការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានសំដែងការព្រួយបារម្ភយ៉ាងខ្លាំងពីអ្វីដែលគេនិយាយថាជាការប្រើប្រាស់កងកម្លាំងមិនសមាមាត្រ ដោយមន្រ្តីអនុវត្តច្បាប់ដែលឆ្លើយតបទៅនឹងអ្នកតវ៉ានៅប្រទេសកម្ពុជា ហើយបានជំរុញឲ្យអាជ្ញាធរ និង កងសន្តិសុខធ្វើការអត់ធ្មត់ខ្លាំបំផុត។

អ្នកនាំពាក្យការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ រ៉ូភើត ខូវីល (Ropert Colville) បានប្រាប់អ្នកសាព័តមាននៅក្រុងហ្សឺណែវថា យើងសូមជំរុញឲ្យអាជ្ញាធរកម្ពុជាធ្វើការស៊ើបអង្កេតដោយហ្មត់ចត់ និង ជាបន្ទាន់ និង ធានាបានពីការទទួលខុសត្រូវពេញលេញរបស់សមាជិកកងសន្តិសុខ ដែលគេបានឃើញថាមានការប្រើប្រាស់កងកម្លាំងមិនសមាមាត្រ និង ជ្រុលហួសហេតុនោះ។

អ្នកនាំពាក្យរូបនេះបានបញ្ជាក់ថា ការត្រួតពិនិត្យមើលបាតុកម្ម ត្រូវស្របនឹងកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ និង បទដ្ឋានអន្តរជាតិ គ្រប់ពេលវេលាទាំងអស់ ក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ ដូចមានចែងក្នុងក្រមសីលធម៌របស់អង្គការសហប្រជាជាតិសម្រាប់មន្រ្តីអនុវត្តច្បាប់ និង គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីការប្រើប្រាស់កងកម្លាំង និង អាវុធរបស់មន្រ្តីអនុវត្តច្បាប់។

មនុស្សប្រាំនាក់ត្រូវបានសម្លាប់កាលពីថ្ងៃទី ៣ ខែ មករា នៅពេលកងកម្លាំងសន្តិសុខធ្វើការបាញ់ប្រហារទៅលើកម្មករកាត់ដេរធ្វើកូដកម្មតវ៉ានៅរាជធានីភ្នំពេញ។ មនុស្ស ២០ នាក់ទៀត រងរបួសដោយសាការបាញ់ប្រហារ និង ការវាយដំ។

យោងតាមការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ កម្មករកាត់ដេរធ្វើកូដកម្មតវ៉ាទាមទារប្រាក់ឈ្នួលខ្ពស់ជាងនេះ បានបន្ថែមសាំងទៅនឹងបាតុកម្មផ្នែកនយោបាយ ដែលរៀបចំឡើងចាប់តាំងពីខែកក្កដា ដោយគណបក្សប្រឆាំង ដើម្បីទាមទារឲ្យនាយករដ្ឋមន្ត្រីហ៊ុន សែន ចុះចេញពីតំណែង និង ការបោះឆ្នោតឡើងវិញ។

អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា សុរិយា ស៊ូប៊ែឌី បានអំពាវនាវឲ្យមានការស៊ើបសួរចំបង ហេតុការណ៍នេះដែលបានកើតឡើងនៅថ្ងៃទី ៣ ខែ មករា នេះ គឺជាលើកទីបីហើយចាប់តាំងពីការបោះឆ្នោតជាសកលនៅខែកក្កដា ឆ្នាំ ២០១៣ ដែលមានវិវាទ ដែលអាជ្ញាធរបានបាញ់ទីលើហ្វូងមនុស្ស និង បណ្ដាលឲ្យស្លាប់ជាច្រើននាក់។

ដោយថ្លែងទៅអ្នកសាព័ត៌មាននៅថ្ងៃនេះ លោក ខូវីល បាននិយាយថា ខណៈពេលការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ កត់សំគាល់ឃើញពីការប្រឈមមុខដែលអាជ្ញាធរជួបប្រទះក្នុងការរក្សាសណ្ដាប់ធ្នាប់សាធារណៈ មន្ត្រីសិទ្ធិមនុស្សនានារបស់អង្គការសហប្រជាជាតិចូលរួមជាមួយ ស៊ូប៊ែឌី ក្នុងការអំពាវនាវឲ្យអ្នកតវ៉ាទាំងអស់ធ្វើការអត់ធ្មត់ជាអតិបរមា។

លោក ខូវីល បាននិយាយថា អំពើហិង្សាដោយជុំក្នុងពេលជួបជុំគ្នាជាសាធារណៈ មិនត្រូវប្រើប្រាស់ជាលេសដើម្បីដកសិទ្ធិសេរីភាពក្នុងការជួបជុំគ្នាដោយសន្តិវិធីរបស់អ្នកដទៃឡើយ ដែលវាជាសិទ្ធិមួយដែលត្រូវទទួលបានការការពារ និង លើកកម្ពស់ដោយអាជ្ញាធរ។

ក្រៅពីនេះ លោកបានកត់សំគាល់ឃើញថា មនុស្ស ២៣ នាក់ រួមមានអនីតិជនម្នាក់ផងដែរ ត្រូវបានគេចាប់ឃុំខ្លួន បន្ទាប់ពីមានការប៉ះទង្គិចគ្នា ហើយគេក៏មិនដឹងពីកន្លែងឃុំខ្លួននោះដែរ។

អ្នកនាំពាក្យនិយាយថា យើងជុំរុញឲ្យអាជ្ញាធរកម្ពុជាអនុញ្ញាតឲ្យអ្នកជាប់ឃុំទាំងនោះបានជួបជាមួយក្រុមគ្រួសាររបស់គេ មេធាវី ហើយបើចាំបាច់ ទទួលបានការថែទាំសុខភាព។ ប្រសិនបើពុំមានការចោទប្រកាន់ពីបទល្មើសកំណត់តាមច្បាប់ទេ គួរតែដោះលែងពួកគេភ្លាម។

សម្រាប់ព័ត៌មានបន្ថែម សូមចូលគេហទំព័រនៃមជ្ឈមណ្ឌលព័ត៌មានរបស់អង្គការសហប្រជាជាតិ http://www.unorg/news។